# សេចក្តីជូនដំណឹង

## ស្តីពីការជ្រើសរើសសិស្សចូលរៀនវគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសសម្លេងភាពយន្ត

ដោយមើលឃើញអំពីសារៈសំខាន់ និងកង្វះខាតអ្នកបច្ចេកទេសសម្លេងក្នុងវិស័យខ្សែភាពយន្តកម្ពុជា មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញ និងទទួលថតភាពយន្តនៅកម្ពុជា នឹងរៀបចំ **វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសសម្លេងភាពយន្ត** នៅខែកញ្ញា ឆ្នាំ២០១៩ខាងមុខនេះ។ វគ្គបណ្តុះបណ្តាលនេះ នឹងផ្តល់ឱកាសដល់អ្នកបច្ចេកទេសភាពយន្តជំនាន់ក្រោយបានសិក្សាស្វែងយល់ចំណេះដឹងបន្ថែមពីមូលដ្ឋានគ្រឹះសំខាន់ៗនៃការយកសំលេង ការកាត់ត-ផ្គុំសំលេង និងការថែទាំឧបករណ៍បច្ចេកទេសសម្លេងផងដែរ។

វគ្គបណ្តុះបណ្តាលបច្ចេកទេសសម្លេងភាពយន្ត នឹងបែងចែកជាបីវគ្គសំខាន់ៗ ដោយមានប្រធានបទខុសៗគ្នា ដែលនឹងបង្ហាត់បង្រៀនដោយ **លោក** Nicolas Volte ដែលជាអ្នកបច្ចេកទេសសម្លេងដែលមានបទពិសោធន៍ និងធ្លាប់ចូលរួមក្នុងការផលិតខ្សែភាពយន្តខ្នាតធំជាច្រើនកន្លងមក រួមទាំងនៅកម្ពុជា។

- វគ្គទី១ “**ការយកសម្លេងផ្ទាល់នៅកន្លែងថត**” ចាប់ពីថ្ងៃទី ២០ ដល់ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៩។
- វគ្គទី២ “**ការកាត់តសម្លេងសម្រាប់ខ្សែភាពយន្ត**” ចាប់ពីថ្ងៃទី ៣០ ខែកញ្ញា ដល់ថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១៩។
- វគ្គទី៣ “**ការផ្គុំសម្លេងសម្រាប់ខ្សែភាពយន្ត**” ចាប់ពីថ្ងៃទី ០៧ ដល់ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៩។

វគ្គបណ្តុះបណ្តាលនេះ រៀបចំដោយ **មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញ និងទទួលថតភាពយន្តនៅកម្ពុជា** ក្រោមការគាំទ្រពី **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** និងម្ចាស់ជំនួយ **ភ្នាក់ងារបារាំងដើម្បីការអភិវឌ្ឍ** (Agence Française du Developpement)។

**លក្ខខណ្ឌជ្រើសរើស**

- អ្នកស្រលាញ់អាជីពក្នុងវិស័យភាពយន្ត
- កំពុងធ្វើការលើវិស័យភាពយន្ត ឬអ្នកបច្ចេកទេសភាពយន្ត
- មានពេលវេលាគ្រាប់គ្រាន់ចូលរួមវគ្គបណ្តុះបណ្តាល
- អ្នកមានបទពិសោធន៍ការងារផ្នែកសំលេងភាពយន្តកាន់តែប្រសើរ
- ការបណ្តុះបណ្តាលមិនតម្រូវឲ្យបង់ប្រាក់ទេ

**ការដាក់ពាក្យស្នើសុំ**

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេបឲ្យបានមុនថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០១៩ តាមរយៈអាស័យដ្ឋានខាងក្រោម៖

- អ៊ីម៉ែល cinetraining@cambodia-cfc.org
- ឬ ផ្ញើមកកាន់ទំព័រ Facebook ផ្លូវការ https://www.facebook.com/contactcfc/
- ឬ មកដាក់ពាក្យនៅមជ្ឈមណ្ឌលយើងខ្ញុំផ្ទាល់ដែលមានអាស័យដ្ឋាន ផ្ទះលេខ ១២៨ ផ្លូវលេខ ២០០ ទល់មុខនាយកដ្ឋានសិល្បភាពយន្ត និងផ្សព្វផ្សាយវប្បធម៌។

សំរាប់ពត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់លេខទូរសព្ទ ០២៣ ២២២ ៩២០។

*****សូមអរគុណ*****